# សិក្ខាសាលាផ្សព្វផ្សាយគម្រោង
## ថ្នាលឧត្តមចំណេះទី១៖ ការលើកកម្ពស់នវានុវត្តន៍អប់រំឧត្តមសិក្សានៅកម្ពុជា

ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារកាំបូឌីយ៉ាណា

## ឯកសារទស្សនៈទាន

**បរិបទ**

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បាននឹងកំពុងអនុវត្តគម្រោងមួយដែលមានឈ្មោះថា «ថ្នាលឧត្តមចំណេះ៖ ការលើកកម្ពស់នវានុវត្តន៍ឧត្តមសិក្សានៅកម្ពុជា»។ គម្រោងដែលមានរយៈពេលពីរឆ្នាំកន្លះនេះ ទទួលបានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍន៍នៅកម្ពុជារបស់អង្គការមូលនិធិអាស៊ី។ គោលបំណងចម្បងរបស់គម្រោងនេះ គឺដើម្បី (១) ផលិតលទ្ធផលស្រាវជ្រាវដែលមានគុណភាពខ្ពស់ និងងាយស្រួលប្រើប្រាស់សម្រាប់ចូលរួមកំណែទម្រង់ និងការអនុវត្តន៍គោលនយោបាយនៅកម្រិតឧត្តមសិក្សានៅកម្ពុជា (២) កសាងចំណេះដឹង ជំនាញ និងសមត្ថភាពរបស់វិទ្យាស្ថាន CDRI ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីក្លាយខ្លួនជាវិទ្យាស្ថានឈានមុខគេ ក្នុងការស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍ទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ និង (៣) បង្កើតភាពជាដៃគូសម្រាប់កិច្ចពិភាក្សាគោលនយោបាយ និងផ្នែកសិក្សាក៏ដូចជា ការស្រាវជ្រាវរវាងវិទ្យាស្ថាន CDRI និងភាគីពាក់ព័ន្ធនានា ដូចជា រាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ទាំងក្នុងនិងក្រៅប្រទេស។

ប្រធានបទស្រាវជ្រាវសំខាន់ៗដែលស្ថិតក្រោមគម្រោងនេះ រួមមាន ការអប់រំស្ទែម អន្តរជាតូបនីយកម្មឧត្តមសិក្សា ការប្រើប្រាស់បច្ចេកវិទ្យាអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសហគ្រិនភាពរបស់និស្សិតកម្ពុជា។ ក្នុងអំឡុងពេលអនុវត្តគម្រោងនេះ វិទ្យាស្ថាន CDRI បានចងក្រងឯកសារស្រាវជ្រាវមួយចំនួន មានជាអាទិ៍ សៀវភៅមួយដែលមានចំណងជើងថា «ការអប់រំ និងបណ្តុះបណ្តាលក្រោយមធ្យមសិក្សានៅកម្ពុជាក្នុងបរិបទសង្គមពុទ្ធិសកល» ឯកសារស្រាវជ្រាវចំនួនពីរដែលពិភាក្សាអំពីគោលគំនិតនៃការអប់រំស្ទែមនៅកម្ពុជា និងការប្រើប្រាស់បច្ចេកវិទ្យាអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីត-១៩ និង អត្ថបទស្រាវជ្រាវចំនួនបួនទៀត ដែលបានចេញផ្សាយនៅលើទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា (CDR)។ មិនតែប៉ុណ្ណោះ ឯកសារស្រាវជ្រាវចំនួនបួនទៀត រួមទាំងអត្ថបទស្រាវជ្រាវចំនួនពីរ និងអត្ថបទសង្ខេបគោលនយោបាយចំនួនពីរផ្សេងទៀត នឹងត្រូវចេញផ្សាយនៅប៉ុន្មានខែខាងមុខនេះ។ ស្របពេលដែលគម្រោងថ្នាលឧត្តមចំណេះទី១នេះ បានចប់ជាស្ថាពរ វិទ្យាស្ថាន CDRI មានសេចក្ដីសោមនស្សរីករាយក្នុងការបង្ហាញលទ្ធផលស្រាវជ្រាវ និងភស្តុតាងនានាដែលបានពីការស្រាវជ្រាវទៅកាន់ភាគីពាក់ព័ន្ធ ដោយសង្ឃឹមថា លទ្ធផលស្រាវជ្រាវទាំងនេះ នឹងក្លាយជាធាតុចូលសំខាន់សម្រាប់ការបង្កើត និងការអនុវត្តន៍គោលនយោបាយនៅកម្ពុជា។

**គោលបំណង**

ជាផ្នែកមួយនៃកិច្ចសន្ទនាជាសាធារណៈ សិក្ខាសាលាផ្សព្វផ្សាយគម្រោងនេះ នឹងប្រមូលផ្តុំភាគីពាក់ព័ន្ធ ដើម្បីចូលរួមពិភាក្សានៅក្នុងកិច្ចពិភាក្សាពេញអង្គទាំងបីនៅក្នុងសិក្ខាសាលានេះ។ គោលបំណងសំខាន់របស់សិក្ខាសាលានេះ គឺ៖

- ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវដែលបានមកពីការសិក្សាក្រោមគម្រោងថ្នាលឧត្តមចំណេះទី១
- ពិភាក្សាអំពីលទ្ធផលស្រាវជ្រាវ ដោយផ្តោតទៅលើបញ្ហា ឧបសគ្គ និងឱកាសដែលអាចកើតមាននៅក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩ ជាពិសេស ទាក់ទិននឹងការសិក្សាតាមប្រព័ន្ធអនឡាញ ការអប់រំស្វែម ការអប់រំសហគ្រិនភាព និងអន្តរជាតូបនីយកម្មឧត្តមសិក្សា
- ផ្តល់ជាវេទិកាសម្រាប់ការពិភាក្សាគោលនយោបាយរវាងភាគីពាក់ព័ន្ធ
- បង្កើតជាអនុសាសន៍គោលនយោបាយដើម្បីចូលរួមពង្រឹងវិស័យឧត្តមសិក្សានៅកម្ពុជា។

**ទម្រង់**

សិក្ខាសាលានេះ នឹងធ្វើឡើងនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ ដោយផ្ទាល់នៅសណ្ឋាគារកាំបូឌីយ៉ាណា និងតាមប្រព័ន្ធអនឡាញតាមរយៈ Zoom)។

**អ្នកចូលរួម**

វិទ្យាស្ថាន CDRI នឹងអញ្ជើញដៃគូពាក់ព័ន្ធប្រមាណ ១០០នាក់ ឱ្យចូលរួមសិក្ខាសាលាផ្សព្វផ្សាយនេះ។ ក្នុងនោះ អ្នកចូលរួម ជាតំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកស្រាវជ្រាវឯករាជ្យធ្វើការនៅក្នុងវិស័យអប់រំ។

**របៀបវារៈ**

| *កាលបរិច្ឆេទ/ម៉ោង* | *សកម្មភាព* |
|---|---|
| *[៨:៣០]* | ការចុះឈ្មោះ |
| *[៩:០០ – ៩:៣០]* | សុន្ទរកថាស្វាគមន៍ ដោយ **បណ្ឌិត អេង នេត្រា** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| | សុន្ទរកថាបើក ដោយ **លោក** Connor Floyd លេខាទី២នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា |
| | ការថតរូបជាក្រុម |
| *[៩:៣០ – ១០:០០]* | សម្រាកអាហារសម្រន់ និងការតាំងបង្ហាញលទ្ធផលស្រាវជ្រាវ |
| *[១០:០០ – ១១:៣០]* | ពិធីសម្ពោធសៀវភៅ៖ ការអប់រំ និងបណ្តុះបណ្តាលក្រោយមធ្យមសិក្សានៅកម្ពុជាក្នុងបរិបទសង្គមពុទ្ធិសកល |

| *កាលបរិច្ឆេទ/ម៉ោង* | *សកម្មភាព* |
| --- | --- |
| *[១០:០០ – ១១:៣០]* | **កិច្ចពិភាក្សាពេញអង្គទី១៖ ការអប់រំ និងបណ្តុះបណ្តាលក្រោយមធ្យមសិក្សានៅកម្ពុជាក្នុងបរិបទសង្គមពុទ្ធិសកល**<br>អ្នកសម្របសម្រួល: **បណ្ឌិត សុង សុភក្តិ** នាយកមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំនៃវិទ្យាស្ថានCDRI<br>វាគ្មិន:<br>**បណ្ឌិត អៀម ភិរម្យ** អ្នកប្រឹក្សាស្រាវជ្រាវនៃវិទ្យាស្ថានCDRI<br>**បណ្ឌិត ឃៀង សុធី** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា<br>**បណ្ឌិត ហេង គ្រេង** ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃអគ្គនាយកដ្ឋានឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា<br>**លោកស្រី យូ សៅកែវខន្តី** អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំនៃវិទ្យាស្ថានCDRI |
| *[១១:៣០ – ១៣:៣០]* | សម្រាកអាហារថ្ងៃត្រង់ |
| *[១៣:៣០ – ១៥:០០]* | **កិច្ចពិភាក្សាពេញអង្គទី២៖ ការបែងចែកជំនាញនៅកម្រិតវិទ្យាល័យ និងជម្រើសមុខវិជ្ជានៅថ្នាក់ឧត្តមសិក្សា**<br>អ្នកសម្របសម្រួល: **បណ្ឌិត ជា ផល** អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំនៃវិទ្យាស្ថានCDRI<br>វាគ្មិន:<br>**បណ្ឌិត កៅ សុវណ្ណសុផល** អនុប្រធានការិយាល័យចុះឈ្មោះចូលរៀន នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា<br>**បណ្ឌិត តាន់ រស្មី** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា<br>**លោកស្រី ស៊ុន ចិន្តា** នាយិកាវិទ្យាល័យក្រុងព្រះសីហនុ<br>**កញ្ញា បេងហុង សិលាបុស្បា** ជំនួយការស្រាវជ្រាវនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មនៃវិទ្យាស្ថានCDRI |
| *[១៥:០០ – ១៥:៣០]* | សម្រាកអាហារសម្រន់ |
| *[១៥:៣០ – ១៧:០០]* | **កិច្ចពិភាក្សាពេញអង្គទី៣៖ ការចូលរួមរបស់សមាជិកមហាវិទ្យាល័យក្នុងដំណើរការអន្តរជាតូបនីយកម្មឧត្តមសិក្សា**<br>អ្នកសម្របសម្រួល: **លោក រស់ វុទ្ធថា** បេក្ខជនបណ្ឌិត សាកលវិទ្យាល័យហុងកុង |

| *កាលបរិច្ឆេទ/ម៉ោង* | *សកម្មភាព* |
| --- | --- |
| | វាគ្មិន:<br>**បណ្ឌិត គី វ៉ារិគន្ធ** សាកលវិទ្យាធិការរងទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ និងស្រាវជ្រាវនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ<br>**បណ្ឌិត ឡេង ភីរម្យ** ទីប្រឹក្សានៃក្រុមប្រឹក្សាជាតិវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍<br>**លោក ហ៊ែល ចាន់ថន** គ្រូបង្រៀន និងអ្នកស្រាវជ្រាវនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា<br>**លោកស្រី តឹក មុយទៀង** អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំនៃវិទ្យាស្ថាន CDRI |
| *[១៧:០០ – ១៧:១៥]* | ការថ្លែងសរុបដោយ **បណ្ឌិត សុង សុភក្តិ** នាយកមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំនៃវិទ្យាស្ថានCDRI<br>សុន្ទរកថាបិទ ដោយ **លោកស្រី** Meloney Lindberg អ្នកតំណាងអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា |

**អ្នករៀបចំកម្មវិធី សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូររបៀបវារៈនៃកម្មវិធីនេះ។*

- ដើម្បីចូលរួមសិក្ខាសាលានេះតាមរយៈប្រព័ន្ធអនឡាញ សូមចូលទៅកាន់ https://zoom.us/meeting/register/tJ0sf-urrzkoHtU2rqj-Gx4ZPkARgxcjyydf ឬស្កេន QR នៅខាងស្តាំនេះដើម្បីធ្វើការចុះឈ្មោះ
- ដើម្បីចូលរួមសិក្ខាសាលានេះដោយផ្ទាល់ លោកអ្នក តម្រូវអោយមានការបង្ហាញកាតចាក់វ៉ាក់សាំងទៅកាន់អ្នករៀបចំកម្មវិធី។ ក្រៅពីនេះ យើងខ្ញុំលើកទឹកចិត្តលោកអ្នកអោយលោកអ្នកអោយពាក់ម៉ាស់រាល់ពេល លាងដៃអោយបានញឹកញាប់ និងអនុវត្តតាមការណែនាំនៃការរក្សាគម្លាត។